ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៣៧៨ សហវ.ប្រក.ហអ

ប្រកាស
ស្តីពី
ការគ្រប់គ្រងនិងអនុវត្តថវិកាសម្រាប់
ការសិក្សាគម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីក្រមសីលធម៌មន្ត្រីមានសមត្ថកិច្ចក្នុងការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- បានឃើញប្រកាសលេខ ៤១១ សហវ.ប្រក ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៨៧ សហវ.ប្រក ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១ ស្ដីពីការបង្កើតគណៈកម្មការវិនិយោគសាធារណៈ
- បានឃើញប្រកាសលេខ ៨៦២ សហវ.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ស្ដីពីការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់)
- បានឃើញប្រកាសលេខ ៥២៣ សហវ-ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះ កំណត់អំពីវិធាននិងនីតិវិធីសម្រាប់ការគ្រប់គ្រងនិងអនុវត្តថវិកាសិក្សាគម្រោង ដើម្បីធានាប្រសិទ្ធភាព សក្តិសិទ្ធភាព និងតម្លាភាព នៃគម្រោងវិនិយោគផ្ទាល់ ក្នុងក្របខណ្ឌគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ ហៅថា ថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់។

**ប្រការ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ដែលទទួលបានថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់។

## ជំពូកទី២

## ថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ និងលក្ខខណ្ឌតម្រូវ

**ប្រការ៣._**

ត្រូវបានបង្កើតនិងគ្រោងថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ ស្របតាមចំណាត់ថ្នាក់នៃមាតិកាថវិកា ក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ។

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង ត្រូវបានអនុញ្ញាតឱ្យគ្រោងថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ ដែលជាកម្មវត្ថុនៃការពិនិត្យសម្រេចទៅតាមលទ្ធភាពនៃថវិកាប្រចាំឆ្នាំ។

ថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់នេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងមុខងាររបស់អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤._**

ការសិក្សាគម្រោង សំដៅដល់ការសិក្សាលើទិដ្ឋភាពពាក់ព័ន្ធ មានជាអាទិ៍ បច្ចេកទេស តម្លៃ ហានិភ័យ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ច្បាប់ ហេតុប៉ះពាល់បរិស្ថាននិងសង្គម ស្របតាមតម្រូវការជាក់ស្តែងនៃការសិក្សាគម្រោង ដោយអនុលោមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រងរៀបចំ និងអនុវត្តគម្រោងវិនិយោគផ្ទាល់ហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ។

**ប្រការ៥._**

គម្រោងដែលជាកម្មវត្ថុនៃការទទួលបានថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ ត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវណាមួយ ដូចខាងក្រោម÷

- គម្រោងដែលស្ថិតនៅក្នុងបញ្ជីគម្រោងត្រូវធ្វើការសិក្សា ដែលទទួលបានការសម្រេចពីគណៈកម្មការអន្តរក្រសួង ឬក្រុមការងារអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង ដោយអនុលោមតាមគោលការណ៍សនិទានកម្ម និងលទ្ធភាពនៃថវិកា
- គម្រោងដែលទទួលបានការសម្រេចឱ្យធ្វើការសិក្សាពីគណៈកម្មការវិនិយោគសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គម្រោងដែលទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការស្នើសុំសិក្សាពីក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង
- គម្រោងដែលសម្រេចឱ្យធ្វើការសិក្សាពីប្រមុខរាជរដ្ឋាភិបាល ឬពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣

## នីតិវិធី និងបែបបទនៃការអនុវត្តចំណាយថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់

### ផ្នែកទី១

### ដំណាក់កាលនៃការអនុវត្តចំណាយថវិកា

**ប្រការ៦._**

នីតិវិធីនៃការអនុវត្តចំណាយថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ រួមមាន ៤ ដំណាក់កាល ដូចខាងក្រោម÷

- ការធានាចំណាយ
- ការអនុវត្តកិច្ចលទ្ធកម្ម
- ការអនុវត្តការសិក្សាគម្រោង
- ការទូទាត់។

## ផ្នែកទី២
## ការធានាចំណាយ

**ប្រការ៧._**

ការធានាចំណាយ គឺជាប្រតិបត្តិការដែលរដ្ឋបង្កើត ឬទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួន ដែលនឹងនាំឱ្យមានចំណាយថវិកា។ ការធានាចំណាយ រក្សាទុកឥណទានថវិកាសម្រាប់ធ្វើការទូទាត់នៅពេលក្រោយ ស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ៨._**

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង ត្រូវស្នើសុំធានាចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារនិងលិខិតយុត្តិការ ដូចខាងក្រោម÷

- លិខិតស្នើសុំធានាចំណាយ
- ឯកសារ ឬគោលការណ៍ឯកភាពឱ្យមានការសិក្សាគម្រោង ដែលមានបញ្ជាក់ច្បាស់លាស់ពីប្រភេទនៃការសិក្សាគម្រោង
- បញ្ជីប៉ាន់តម្លៃការសិក្សាគម្រោង
- លិខិតយុត្តិការចំណាយផ្សេងៗទៀត តាមការចាំបាច់។

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង ក៏អាចស្នើសុំធានាចំណាយដោយប្រមូលផ្តុំការសិក្សាគម្រោងច្រើនរួមគ្នា។

**ប្រការ៩._**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានអគ្គនាយកដ្ឋានថវិកាជាសេនាធិការ អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាពសាធារណៈម្ចាស់គម្រោង ឬភាគីពាក់ព័ន្ធ ដើម្បីពិភាក្សាបន្ថែមអំពីការស្នើសុំធានាចំណាយ។

**ប្រការ១០._**

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង អាចស្នើសុំថវិកាបុរេប្រទានសម្រាប់ផ្តល់ជូនអ្នកសិក្សាគម្រោងដែលជាអង្គភាពរដ្ឋប៉ុណ្ណោះ។ ថវិកាបុរេប្រទានត្រូវបានផ្តល់ជូនមិនលើសពី ៤០% នៃទឹកប្រាក់ធានាចំណាយ។ ក្នុងករណីចាំបាច់ អាចផ្តល់ជូនជាអតិបរមាត្រឹម ៦០% នៃទឹកប្រាក់ធានាចំណាយ ស្របតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អ្នកសិក្សាគម្រោង មិនអាចបង្វែរថវិកាបុរេប្រទានសម្រាប់ការសិក្សាគម្រោង ទៅប្រើប្រាស់ជាគុណប្រយោជន៍សម្រាប់ការងារផ្សេងទៀតបានទេ។

ក្នុងករណីការសិក្សាគម្រោងមិនអាចអនុវត្តទៅបានដោយសារកត្តាជាយថាហេតុណាមួយ ថវិកាបុរេប្រទានដែលទទួលបាននោះ ត្រូវបង្វែរចូលថវិការដ្ឋវិញ។

សម្រាប់គម្រោងមានលក្ខណៈចាំបាច់និងបន្ទាន់ដែលមានការសម្រេចជាមុនពីប្រមុខរាជរដ្ឋាភិបាល ឬពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការផ្តល់ថវិកាបុរេប្រទានអាចត្រូវបានអនុញ្ញាតផ្តល់ជូនជាមុន តាមការស្នើសុំរបស់ក្រសួង

ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង ដោយតម្រូវឱ្យស្នើសុំធានាចំណាយនិងផ្តល់ឯកសារពាក់ព័ន្ធតាមក្រោយ ដើម្បីបំពេញនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ១១._**

ការស្នើសុំថវិកាបុរេប្រទាន ត្រូវភ្ជាប់មកជាមួយនូវឯកសារនិងលិខិតយុត្តិការ ដូចខាងក្រោម÷

- លិខិតស្នើសុំថវិកាបុរេប្រទាន
- ឯកសារ ឬគោលការណ៍ឯកភាពឱ្យមានការសិក្សាគម្រោង ដែលមានបញ្ជាក់ច្បាស់លាស់ពីប្រភេទនៃការសិក្សាគម្រោង
- បញ្ជីប៉ាន់តម្លៃការសិក្សាគម្រោង និងប្រតិទិនអនុវត្តការសិក្សាគម្រោង
- លិខិតយុត្តិការចំណាយផ្សេងៗទៀត តាមការចាំបាច់។

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង ក៏អាចស្នើសុំថវិកាបុរេប្រទានរួមគ្នាជាមួយការស្នើសុំធានាចំណាយតែម្តងក្នុងលិខិតតែមួយ។

## ផ្នែកទី៣
## ការអនុវត្តកិច្ចលទ្ធកម្ម

**ប្រការ១២._**

អ្នកសិក្សាគម្រោង អាចជាក្រុមហ៊ុនទីប្រឹក្សា ទីប្រឹក្សាឯកត្តជន ឬអង្គភាពរដ្ឋចំណុះក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ។

ក្រោយទទួលបានការធានាចំណាយថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោងត្រូវដំណើរការកិច្ចលទ្ធកម្មឱ្យបានត្រឹមត្រូវតាមវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្ម ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន។

## ផ្នែកទី៤
## ការអនុវត្តការសិក្សាគម្រោង

**ប្រការ១៣._**

អ្នកសិក្សាគម្រោង ត្រូវអនុវត្តទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាការសិក្សាគម្រោង និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការសិក្សាគម្រោង។

អ្នកសិក្សាគម្រោង ត្រូវគោរពប្រតិបត្តិទៅតាមក្រមសីលធម៌មន្ត្រីមានសមត្ថកិច្ច ក្នុងការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធបវន្តសាធារណៈ ដូចមានចែងក្នុងអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១។

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង ត្រូវចាត់ចែងត្រួតពិនិត្យ វាយតម្លៃ និងបញ្ជាក់លើលទ្ធផលនៃការសិក្សាគម្រោង។

លទ្ធផលនៃការសិក្សាគម្រោង ជាកម្មវត្ថុនៃការពិនិត្យផ្ទៀងផ្ទាត់និងវាយតម្លៃដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## ការទូទាត់

**ប្រការ១៤._**

ការទូទាត់ថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ ត្រូវអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យា ដោយផ្ទេរត្រង់ពីគណនីទោលរតនាគារ ទៅគណនីរបស់អ្នកសិក្សាគម្រោង។

**ប្រការ១៥._**

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង មានកាតព្វកិច្ចស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីទូទាត់ជម្រះថវិកាបុរេប្រទានឱ្យបានទាន់ពេលវេលាស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ដោយមានភ្ជាប់មកជាមួយនូវឯកសារនិងលិខិតយុត្តិការ ដូចខាងក្រោម÷

- លិខិតស្នើសុំទូទាត់ជម្រះថវិកាបុរេប្រទាន
- អាណត្តិនិយ័តកម្មជម្រះថវិកាបុរេប្រទាន
- កិច្ចសន្យាការសិក្សាគម្រោង
- របាយការណ៍ចំណាយថវិកា
- សក្ខីបត្រចំណាយ
- របាយការណ៍វឌ្ឍនភាពការសិក្សាគម្រោង ដែលមានការបញ្ជាក់ពីក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង
- លិខិតយុត្តិការចំណាយផ្សេងៗទៀត តាមការចាំបាច់។

**ប្រការ១៦._**

ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង ត្រូវស្នើសុំទូទាត់ថវិកាតាមលក្ខខណ្ឌនៃកិច្ចសន្យា ដោយមានភ្ជាប់មកជាមួយនូវឯកសារនិងលិខិតយុត្តិការ ដូចខាងក្រោម÷

- លិខិតស្នើសុំទូទាត់ថវិកា
- អាណត្តិបើកប្រាក់ សលាកប័ត្រកត់ត្រាចំណាយថវិកានិងត្រួតពិនិត្យហិរញ្ញវត្ថុ ដីកាអមបញ្ចេញអាណត្តិបើកប្រាក់ និងដីកាអមលិខិតយុត្តិការ
- លិខិតផ្តល់ធានាចំណាយចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុស្ទង់តម្លៃ/ចរចាថ្លៃ/ពិគ្រោះថ្លៃ/ដេញថ្លៃ
- កិច្ចសន្យាការសិក្សាគម្រោង (ករណីជាក្រុមហ៊ុនឯកជន ត្រូវមានពន្ធប្រថាប់ត្រា)
- របាយការណ៍ចំណាយថវិកា
- កំណត់ហេតុវាយតម្លៃបញ្ជាក់ពីវឌ្ឍនភាពការសិក្សាគម្រោង/កំណត់ហេតុប្រគល់-ទទួលដែលមានភ្ជាប់មកជាមួយនូវរបាយការណ៍នៃការសិក្សាគម្រោង

- ច្បាប់អាជីវកម្ម និងប័ណ្ណប៉ាតង់ (ប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់) (ច្បាប់ចម្លងមានការបញ្ជាក់ទទួលស្គាល់)
- លិខិតយុត្តិការចំណាយផ្សេងៗទៀត តាមការចាំបាច់។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ១៧._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៤កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ